# នៅមុខខ្លោងទ្វាររោងចក្រ

ឈុតទី 3/6



អង្គការ
ពលកម្ម
អន្តរជាតិ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា


ស្តាប់ណា៎ ពួកឯង.....បើពួកឯងមិនគាំទ្រយើងឱ្យកាន់តំណែងអនុប្រធានសហជីពនេះទេ ពួកយើងប្រាកដជាយ៉ាប់ខ្លួនទាំងអស់គ្នាមិនខាន ។ ពេលដែលយើងជាប់ជាអនុប្រធានសហជីពហើយនោះ ពេលនោះ យើងប្រាកដជាអាចកំចាត់អាថាវ៉ាចោល ហើយឡើងធ្វើជាប្រធានសហជីពខ្លួនឯងតែម្តង!
រឿងនេះបានប្រយោជន៍តែឯងហ្នឹង....ហើយចុះពួកយើង?
ពួកឯងសុទ្ធតែជំពាក់គុណយើង! ពួកឯងត្រូវចាំថា ពេលបានលាភសក្ការៈហើយ ត្រូវចេះដឹងគុណអ្នកដែលគេជួយផង!
នៅគ្រាដដែលនោះ...
សូមបងប្អូនជួយគាំទ្រខ្ញុំនៅក្នុងការបោះឆ្នោតជ្រើសរើសអនុប្រធានសហជីពនេះផង.... ខ្ញុំនឹងប្រឹងប្រែង ធ្វើយ៉ាងណាឱ្យលក្ខខណ្ឌការងាររបស់កម្មករក្នុងរោងចក្រយើងនេះមានភាពប្រសើរឡើង ហើយ... សូមអ្នកទាំងអស់គ្នាអញ្ជើញមកស្តាប់ខ្ញុំឡើងនិយាយផង....


មិនអីទេស៊ីណា ពួកខ្ញុំគាំទ្រឯង ពួកខ្ញុំក៏ចង់ដឹង ដែរថា ពេលឯងជាប់ជាអនុប្រធានសហជីពហើយ ឯងអាចជួយពួកខ្ញុំអីខ្លះ
ពេលរសៀលនៅក្នុងរោងចក្រ
WB


នែ៎ ម្នាក់នោះ...ឈប់! ធ្វើអីហ្នឹង? ខ្ញុំឃើញឯងមុញដាក់អីចូលក្នុងអាវ.....? មើល៍....ខ្ញុំឆែកមើលសិន.. ..ឯងយកទៅលាក់ណាមុញ?
អត់ទេបង....ខ្ញុំយកទុកវិញហើយតើ កុំប្រាប់គេអីបង....បើគេគិតថាខ្ញុំលួចរបស់ពីរោងចក្រ ខ្ញុំច្បាស់ជាអស់ការងារធ្វើមិនខានទេ...
ស្រីឡែត!!! ម៉េចក៏ឯងធ្វើអញ្ចឹងម្នាស់? ឯងធ្វើការនៅទីនេះជាមួយខ្ញុំយូរណាស់មកហើយ ហើយឯងក៏ដឹងដែរថា កន្លែងនេះតឹងរ៉ឹងណាស់ចំពោះកម្មករណាដែលលួចឥវ៉ាន់....!
អេ៎...នែ៎...ឈប់សិន! .... ហើយប្អូនឯងនាំស្រីឡែតទៅណាហ្នឹង? មានរឿងអី?....ខ្ញុំគឺជាអ្នកតំណាងកម្មករនៅក្នុងរោងចក្រនេះណា!
កុសល នេះមិនមែនជារឿងបងទេ..... ខ្ញុំឃើញនាងលួចឥវ៉ាន់រោងចក្រ
ស៊ីតេ? គ្រាន់តែមួលប៉ុន្មានដើមហ្នឹង! ហើយគ្រាន់តែរឿងកំប៉ិកកំប៉ុកប៉ុណ្ណឹង ចាំបាច់ទៅនាំរឿងឱ្យវែងឆ្ងាយធ្វើអី? ការងារធំដុំផ្សេងទៀតម៉ាត់ខរម៉េចក៏មិនទៅធ្វើ! រឿងនេះទុកឱ្យខ្ញុំដោះស្រាយ....ហើយ នាងមានការងារអីផ្សេងធ្វើ ទៅធ្វើចុះ....


បងកុសល....សន្តិសុខគាត់និយាយ ត្រូវហើយ....បើបងចង់ជួយនិយាយឱ្យ ស្រីឡែត បងមកជាមួយពួកខ្ញុំទៅបន្ទប់ លោកប្រធានហ្នឹងទៅអញ្ចឹង...
អញ្ជើញចូល....
សូមទោសលោក....ខ្ញុំមានបញ្ហាចង់ឱ្យលោកជួយដោះ ស្រាយបន្តិច....ខ្ញុំឃើញកម្មករម្នាក់នេះលួចកាំបិតពីរោងចក្រ ការងារខ្ញុំគឺ ត្រូវតែរាយការណ៍ជូនលោកឱ្យបានជ្រាបដែរ
អឺ....លោកអ្នក...ខ្ញុំដឹងថាលោក រវល់រៀបចំការងារធំៗជា ច្រើនទៀតក្នុងរោងចក្រ...
បើមិនអីទេ រឿងនេះលោកទុកឱ្យខ្ញុំ ដោះស្រាយក៏បានដែរ ហើយខ្ញុំសូមធានាថា មិនឱ្យមាន រឿងអញ្ចឹងកើតឡើងទៀតជាដាច់ខាត
សូមស្ងាត់មាត់បន្តិចទៅកុសល....រឿង នេះធ្ងន់ធ្ងរណាស់ណា! ហើយបើនិយាយទៅ ខ្ញុំមិនដឹងថា ហេតុអ្វីក៏លោកត្រូវមាន វត្តមាននៅទីនេះផងដែរទេ!
មើល៍ អ្នកណាក៏ដោយឱ្យតែបានលួចរបស់ របរពីក្នុងរោងចក្រយើងនេះ ត្រូវតែនាំខ្លួន យកមកដោះស្រាយយ៉ាងតឹងរ៉ឹងជាទីបំផុត ហើយក៏គ្មាននរណាម្នាក់អាចគេចរួច បានទាំងអស់ ខ្ញុំមិនរវល់ថា
អ្នកលួចនោះ ជាអ្នកគ្រប់គ្រង រឺក៏ ជាកម្មករនោះទេ
ស្រីឡែត លោកនាយកនិយាយ ត្រូវ ច្បាប់ការងារបានចែងយ៉ាងច្បាស់ ថា បុគ្គលិកណាដែលត្រូវបានចាប់បាន ថាបានលួចរបស់របរ បុគ្គលិកម្នាក់នោះ នឹងអាចបញ្ឈប់ពីការងារបាន ដោយ នេះជាបទល្មើសកំរិតធ្ងន់


ប្រាប់ខ្ញុំតាមត្រង់មក.... តើនាងមានបានលួចឥវ៉ាន់មែនពិតមែនឬ?
ចាស លោក ខ្ញុំ...បានលួចមែន.....តែ......
អ្នកទាំងអស់គ្នាដែលជាកម្មករទៀតក៏ ប្រហែលជាស្មាន ថា យើងមិនចាប់អារម្មណ៍នឹងការលួចសម្ភារៈបរិក្ខារពីរោងចក្រនេះទេ ....ប៉ុន្តែតាមពិតអំពើលួចជាមូលហេតុក្នុងការបញ្ឈប់ពីការងារបាន!
បង....មានរឿងអីហ្នឹង?
ស្រីខ្មៅគស់ណាស់មិនល្អ...នាងលួចឥវ៉ាន់ក្នុងរោងចក្រ ហើយត្រូវបានគេបញ្ឈប់បាន.....រឿងនេះខ្ញុំមិនអាចជួយនាងបានទេ ព្រោះច្បាប់ការងារបានចែងយ៉ាងច្បាស់ថាលួចជាមូលហេតុដែលនិយោជកអាចបញ្ឈប់កម្មករពីការងារ...
តែធ្វើអញ្ចឹងត្រឹមត្រូវដែរឬទេ? នាងក៏ជាសមាជិកសហជីពដែរ...ហេតុអីក៏យើងមិនជួយនាងផងទៅ
មិនបានទេ...សហជីពយើងមិនអាចធ្វើការប្រឆាំងចំពោះបញ្ហានេះបានទេ ព្រោះវាជាច្បាប់ដែលគេដាក់អនុវត្តទៅលើគ្រប់បណ្ដារោងចក្រកាត់ដេរ
ចុះកម្មករយើងមានដឹងថានេះជាច្បាប់ទេ?
ជាការល្អ នៅពេលដែលគេនិយោជក ឱ្យធ្វើការនៅកន្លែងនេះ គឺគេប្រាប់ពីបញ្ហានេះអស់ហើយប៉ុន្តែទោះយ៉ាងណាក៏ដោយ ពួកយើងត្រូវតែលើកឡើងរឿងនេះទៀត យើងត្រូវប្រើប្រាស់វិធីយ៉ាងណាអប់រំសមាជិកក្នុងសហជីពរបស់យើងឱ្យបានយល់ដឹងពីផលវិបាកនៃការលួចរបស់របរពីរោងចក្រ
ត្រូវហើយបង....ខ្ញុំមានគំរោងថានឹងជួបនិយាយជាមួយកម្មករនៅថ្ងៃស្អែកនេះ នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់ខ្ញុំ .....ខ្ញុំនឹងនិយាយអំពីអ្វីដែលខ្ញុំនឹងធ្វើ ដើម្បីជួយឱ្យកម្មកររបស់យើងយល់ដឹងកាន់តែច្បាស់អំពីច្បាប់ការងារ
ថ្ងៃបន្ទាប់នៅកន្លែងដឹកជញ្ជូនឥវ៉ាន់
យើងប្រាប់ឯងទៅចុះ កាលដែលយើងជួយឯងឱ្យបានការងារនេះធ្វើ នោះបានន័យថាឯងជំពាក់គុណយើងមួយហើយ....ឥឡូវដល់ពេលដែលឯងត្រូវសងគុណយើងវិញហើយ
តែកុំសង...កាលណោះខ្ញុំបានជូនសងគុណបងរួចហើយតើ រឿងនេះបើគេដឹង ខ្ញុំអាចអស់ការងារធ្វើណាបង....


មិនចាំបាច់ទៅឈរសញ្ញាជាមួយយើងទេ យើងនឹងចាត់ចែងជួយសារ៉ៅចេញការងារឱ្យប្រធានគ្រប់គ្រងរោងចក្រយើងនេះ ហើយខ្ញុំនឹងជួយធ្វើការងារមួយនេះឱ្យយើងផងដែរទៅ វាមិនទៅខុសគ្នាស៊ី?
កុសល....លោកប្រធាន គាត់គឺជាប្រធានគ្រប់គ្រងរោងចក្រនេះ គាត់ចង់ធ្វើអីក៏បានដែរ....
ស្ដាប់យើងណាកាន់ប្អូនប្រុស....តើអ្នកណាដែលចេញមុខឃាត់ផ្ដាក់ គ្រប់គ្រងកុំឱ្យស៊ើបពីប្រវត្តិការងារបង ដែលពីមុនត្រូវគេដេញចេញពីការងារ ដោយសារតែបងលួចកាត់រោងចក្រនោះ? ប្រាប់យើងមក?!.....មើលនេះ....យើងមានក្រដាសដែលអាចបើកឱ្យជាក់ពីរឿងរបស់ខាងស៊ីណាបាន.....
ដូចដែលអ្នកទាំងអស់គ្នាដឹងស្រាប់ហើយថា នៅមិនដល់១ខែទៀតទេ ការបោះឆ្នោតជ្រើសរើសអនុប្រធានសហជីពនឹងមកដល់ ខ្ញុំចង់ជួយអ្នកទាំងអស់គ្នាឱ្យយល់ដឹងអំពីច្បាប់ការងារ
ស៊ីណា...! បងដូចជាបងប្អូនពុកយើងអញ្ចឹង! ពួកយើងទុកចិត្តបង!
អ្នកទាំងអស់គ្នាសុទ្ធតែដឹងហើយមែនទេថា តើមានរឿងអ្វីកើតឡើងចំពោះ ស្រីខ្មៅ កាលពីម្សិលមិញ ច្បាប់ការងារបានចែងយ៉ាងច្បាស់ថា ការបន្ទុំ គឺជាការប្រព្រឹត្តកំហុសធ្ងន់ ហើយចំនុចនេះ និយោជករបស់យើងអាចបញ្ឈប់ការងាររបស់យើងភ្លាមៗតែម្ដង ។ បងប្អូនប្រហែលជាគិតថា គឺរឿងស្រីខ្មៅ គឺជារឿងតូចតាចហើយមិនសមនឹងទទួលនូវការដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបែបនេះទេ
ប៉ុន្តែយើងត្រូវចាំថា ច្បាប់ការងារត្រូវបានធ្វើឡើងដើម្បីការពារប្រយោជន៍យើងជាកម្មករ ក៏ដូចជានិយោជកផងដែរ ។ អ្នកទាំងអស់គ្នាសូមគិតទៅមើល តើវាមានអ្វីកើតឡើងសម្រាប់ក្រុមការដែលស្រីខ្មៅគេទាញយករបស់ពីក្នុងរោងចក្រ ហើយត្រូវបញ្ឈប់ពីការងាររបស់ខ្លួនដូច្នេះ? បន្ទាប់ពីសួរហើយ គឺអស់ការងារធ្វើ មិនដែលមានលុយកាក់ដើម្បីទៅចិញ្ចឹមក្រុមគ្រួសារ ហើយនៅមានសាមានបញ្ហាការដែលបញ្ឈប់ការងារនេះទៀត បើបងប្អូនជានិយោជកវិញ តើបងប្អូនទុកចិត្តគាត់ដែរទេ?
WB


ខណៈពេលនៅបន្ទប់សន្តិសុខ
សួស្តី...មានដៃកកេះ ទេ?
អរគុណ... សុខសប្បាយ ទេលោក?
មិនអីទេ.. ថ្ងៃនេះ ក្តៅណាស់
បងស៊ីណា.... ហើយអ្វីនេះបង...? ខ្ញុំដូចជាអត់យល់ទេទៀតកំ... អាវនេះម៉ោពីផ្នែកផលិតកម្មតើ... ហេតុអីបានជាវានៅក្នុងកាបូបបងវិញ?
ខ្ញុំ....ខ្ញុំមិនដឹងទេ.....ខ្ញុំពិតជាអត់ដឹងមែន.....ខ្ញុំអត់បានយកអាវនេះទេ ខ្ញុំហ៊ានស្បថ
បង....អញ្ជើញបងម៉ោកន្លែងផែកនេះ កម្មករម៉ាភ្លែតម៉ោ ខ្ញុំចាប់បានអ្នកលួចឥវ៉ាន់ទៀតហើយ.....
!?
ទទួលបាន...ខ្ញុំចេញទៅហើយ....ហើយចុះអ្នកណាគេហ្នឹង?
តើបងស៊ីណា....


មួយសន្ទុះក្រោយមក នៅឯបន្ទប់លោកប្រធាន
គុក
គុក
សូមទោសលោក.... ខាងខ្ញុំចាប់បានកម្មករលួចឥវ៉ាន់ក្នុងរោងចក្រយើងទៀតហើយ
ហើយនេះជាពេលស្អីទៀតហ៎...? មិនឃើញខ្ញុំ ហើយនិងអ្នកស្រីអនុប្រធាន កំពុងជាប់រវល់ពិភាក្សាការងារជាមួយថៅកែរោងចក្រទេរឺ?
ឱ្យខ្ញុំសូមទោសពីរឿងនេះផងលោក....
មិនអីទេ..ប្រសិនបើរឿងនេះសំខាន់ លោកអញ្ជើញដោះស្រាយចុះ....
ឱ្យខ្ញុំសូមទោសផងលោក....នេះមកពីខ្ញុំគិតថារឿងនេះសំខាន់...
បាទ...មិនអីទេអញ្ជើញ....
នេះ...ខ្ញុំដូចជាមិនយល់សោះទៀតអ៎....ក្រែងនាងឈ្មោះស៊ីណា ដែលបានជួយដោះស្រាយបញ្ហាលុយថែមម៉ោងកម្មករកាលពីប៉ុន្មានខែមុននេះទេអ្វី? ខ្ញុំថែមទាំងលឺគេថា នាងបានឈរឈ្មោះបោះឆ្នោតជាអនុប្រធានសហជីពកម្មករទៀត ចុះហេតុអីឥឡូវនាងបែរជាមកឈរនៅពីមុខខ្ញុំដោយសារតែរឿងលួចឥវ៉ាន់ពីរោងចក្រទៅវិញ?


លោក....រឿងនេះច្បាស់ជាមានបញ្ហាពិតមិនស្រួលហើយ ខ្ញុំមិនដែលបានលួចអ្វីពីរោងចក្រទេ ខ្ញុំក៏មិនយល់ថា រឿងហេតុនេះវាកើតឡើងយ៉ាងម៉េចដែរ ប៉ុន្តែខ្ញុំសូមធានាអះអាងចំពោះលោកប្រធាន ថាខ្ញុំអត់បានលួចអាវនេះទេ...
លេសដដែលៗឱ្យរាល់តែដង...! .... "មិនមែនខ្ញុំទេលោក" .... "ខ្ញុំអត់មានដែលលួចអីទេ" គ្មាននរណាម្នាក់ធំជាងច្បាប់នោះទេ!....ត្រឹមត្រូវទេលោក?
អ៊ែ ស៊ីណា.....ខ្ញុំមិនជឿថា រឿងនេះនាងមិនបានធ្វើនោះទេ.... ពួកយើងទាំងអស់គ្នាសុទ្ធតែគិតថាស៊ីណានេះជាមនុស្សស្មោះត្រង់ ហើយជាបេក្ខជនម្នាក់ដែលសក្តិសមបំផុតសំរាប់តំណែងជាអនុប្រធានសហជីពនេះ.... បើនិយាយទៅ ខ្ញុំថែមទាំងបានគិតថានឹងឈប់ឈរឈ្មោះ ហើយឱ្យនាងឈរតែម្នាក់ឯងទៀតផង....
បើលោកនៅតែនិយាយអត់បានការអញ្ចឹងទៀត បិទមាត់វិញទៅកុសល.....
អឺ....បាទអត់ទេលោក.....តាមពិតទៅ ខ្ញុំគ្រាន់តែចង់មកជំរាបលោកថា ខ្ញុំមិនមែនចង់មកនិយាយប្រឆាំងករណីស៊ីណានេះទេ ក្នុងករណីនេះ យើងប្រហែលជាគ្មានជំរើសអ្វីផ្សេងទៀតក្រៅពីព្យួរបេក្ខភាពស៊ីណា ហើយខ្ញុំបន្តឈរឈ្មោះបោះឆ្នោត
ស៊ីណា...ខ្ញុំសូមព្យួរការងារនាងមួយរយៈសិន ដើម្បីឱ្យខាងខ្ញុំធ្វើការស៊ើបអង្កេតទៅលើរឿងនេះឱ្យបានច្បាស់....
សូមអត់ទោសលោកប្រធាន ខ្ញុំបានស្គាល់ស៊ីណាយូរណាស់មកហើយ នាងជាមនុស្សស្មោះត្រង់ និងគួរឱ្យទុកចិត្តណាស់....ខ្ញុំជឿថា នាងមិនអាចទៅលួចរបស់ពីរោងចក្រ ខ្ញុំថាប្រាកដជាមាននរណាម្នាក់ផ្សេងទៀតពាក់ព័ន្ធនៅក្នុងរឿងនេះដែរមិនខាន....ខ្ញុំគិតថា យើងគួរតែយកខ្សែអាត់វីដេអូដែលថតចាប់សកម្មភាពនៅក្នុងរោងចក្រយើងមកចាក់មើល
ដារ៉ា.... បើកាំមេរ៉ាថតចាប់បានរឿងអីដែលមិនស្រួលនោះ សន្តិសុខដែលយាមមើលអេក្រង់ទូរទស្សន៍ប្រាកដជាបានឃើញហើយ
ត្រូវហើយដារ៉ា....ឯងឈប់ធ្វើឱ្យខាតពេលគេគ្រប់គ្នាទៅ សន្តិសុខនៅក្នុងរោងចក្រយើងនេះ ពូកែៗណាស់ បើមានករណីដូចដែលឯងនិយាយនេះមែន ពួកគេប្រាកដជាចាប់បានភ្លាមៗមិនខាន




ពីរបីនាទីក្រោយមក អ្នកទាំងអស់ជុំគ្នាដើម្បីមើលខ្សែអាត់វីដេអូ




អឺ....មិនមែនទេលោក.... រឿងនេះមិនមែនដូចលោកគិតអញ្ចឹងទេ....អាវដែលខ្ញុំពាក់គឺសំរាប់.....
តើលោកគិតថាលោកផ្តល់ជំនួយដល់កម្មករយ៉ាងម៉េចទៅ នៅពេលដែលលោកខំស្រែកកោកៗថា កុំឱ្យកម្មករលួចឥវ៉ាន់ តែលោកខ្លួនឯង បែរជាអ្នកលួចទៅវិញនោះ? រៀបចំឥវ៉ាន់របស់លោក ហើយចេញពីរោងចក្រខ្ញុំឥឡូវនេះភ្លាម!
អ្នកស្រីអនុប្រធាន.....ចាប់ពីពេលនេះទៅខ្ញុំសូមតែងតាំងអ្នកស្រីឱ្យឡើងធ្វើជាប្រធានគ្រប់គ្រងរោងចក្របណ្តោះអាសន្នសិន ។ ការងារចម្បងដែលខ្ញុំចង់ឱ្យអ្នកស្រីធ្វើនោះ គឺត្រូវអនុវត្តយ៉ាងណាឱ្យពួកគេយល់ថា ការលួចរបស់របរពីរោងចក្រ មិនមែនត្រូវបានអត់ឱនឱ្យនោះឡើយ
ខ្សែអាត់នៅតែបន្តបញ្ចាំង
ស៊ីណា...! នោះ....មើលទៅ! អ្នកទាំងអស់គ្នាមើលចុះ ...ឃើញទេ? ស៊ីណា...មើលមើល៍... គេកំពុងតែដាក់អ្វីម្យ៉ាងចូលទៅក្នុងកាបូបរបស់នាង
ត្រូវហើយៗ...ខ្ញុំដាក់កាបូបខ្ញុំនៅក្នុងហ្នឹង.....ហេតុអីក៏មានគេធ្វើអញ្ចឹងមកលើខ្ញុំ....?
បងកុសល.....ពេលដែលស៊ីណាកំពុងជាប់និយាយជាមួយកម្មកររោងចក្រយើងកាលពីថ្ងៃមិញ ខ្ញុំឃើញបង ណារ៉ុះស៊ុសឆ្លាជាមួយម្នាក់ដែលនៅក្នុងខ្សែអាត់វីដេអូទៀតក៏.....
អត់...អត់ទេ...តែបើនិយាយទៅ ខ្ញុំម៉ែៗ ដើរនិយាយជាមួយគេឯងពេញតែរោងចក្រហ្នឹង ព្រោះការងារខ្ញុំតែប៉ុណ្ណឹងទៅហើយ ។ ចុះមិនបានឃើញរូបយើងនៅក្នុងខ្សែអាត់វីដេអូនេះផង ចុះឯងនាំលើករឿងនេះមកនិយាយធ្វើអី?
...អឺ...សូមទោសណា ខ្ញុំមានការងារច្រើនត្រូវធ្វើ....សុំលាទៅមុនសិនហើយ...


បងកុសល....បង! ឈប់សិន...! ខ្ញុំមានរឿងចង់និយាយជាមួយបងបន្តិច....
យ៉ាងម៉េចទៀតហើយ? ក្រែងយើងបាននិយាយជាមួយឯងចប់អស់ហើយកាលពីថ្ងៃមុន..
កុសល ខ្ញុំចង់ឱ្យមានភាពយុត្តិធម៌ ហើយក៏ចង់ឱ្យកាសែតរបស់បងឱ្យតម្លៃដល់បញ្ហាទាំងអស់នេះដែរ ខ្ញុំឃើញបងនៅជាមួយម្នាក់
ផ៉ាច ផាច
អាប្អូនដាភ័....កុំចង់ម៉ោលេងល្បែងនេះជាមួយយើងឱ្យសោះ.....ឯងអាចឈឺខ្លួន.... រឺក៏... ដូច្នេះបើឯងចង់លេងល្បែងនេះ ត្រូវប្រយ័ត្នផង ព្រោះឯងមានតែផ្លូវចាញ់តែប៉ុណ្ណោះ!
ឯងឃើញទេ....បើយើងមានជាប់ពាក់ព័ន្ធនៅក្នុងរឿងនេះ អាម្នាក់ម៉ិញប្រាកដជាស្រែកចោទប្រកាន់យើងបាត់ទៅហើយ! ប្អូនប្រុស យើងប្រាប់ឯងជាលើកចុងក្រោយទៅចុះណា....កុំម៉ោរវល់នឹងរឿងយើង!!
សូមបងចាំសម្ដីខ្លួនឯងផង....! គ្មាននរណាធំជាងច្បាប់នោះទេ! លើកនេះប្រហែលជាបងអាចគេចផុតពីអ្វីដែលបងបានធ្វើមែន ប៉ុន្តែទីបំផុតពេលវេលាគង់តែបញ្ជាក់ឱ្យឃើញសខ្មៅមិនខាន!

**សេចក្តីថ្លែងអំណរគុណ**

សៀវភៅនេះត្រូវបានរៀបរៀង និង ផលិតដោយបុគ្គលិករបស់អង្គការ ILO ***គំរោងរោងចក្រកាត់ដេរប្រសើរ នៅកម្ពុជា*** លោក ខនស៍ ប៊ិយ, លោក ជុំ ផល្លី, អ្នកស្រី នូ ការី, កញ្ញា ណាង ធន្និ, អ្នកស្រី យស់ សុធា និង លោក វ៉ុង សីណុ ។ អង្គការ ILO សូមថ្លែងអំណរគុណជាពិសេសចំពោះ លោក ន៉ិក វ៉ូដ (Navigator Communications) កញ្ញា ម៉ុម ផល្លីកា, លោក ម៉ៅ សុភក្ត្រ, លោក ឈិន ស៊ីណាក់, អ្នកនាង ស្វែង សុជាតា, លោក ទៅ ពិសាន់, កញ្ញា វ៉ាថា លោក ផន់ សុភី និង កញ្ញា កែវ ពេជ្រជិនី (ជាតួសម្តែង ដែលត្រូវបានគេថតយកមកធ្វើរូបថត) សំរាប់ការចូលរួមវិភាគទានរបស់ពួកគេ ដើម្បីផលិតជាសៀវភៅ នេះឡើង ។

**វិចិត្រគំនូរដោយ**

លោក ហូសេ អែនស៊ីណា
Jose Encinas jose@tonle.net

**ឧបត្ថម្ភថវិកាដោយ**

សៀវភៅនេះត្រូវបានផលិតឡើងក្រោមការឧបត្ថម្ភថវិកា តាមរយៈកិច្ចព្រមព្រៀងរួមគ្នារវាង ទីភ្នាក់ងារ សហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍ អន្តរជាតិ USAID និង អង្គការ ILO ***គំរោងរោងចក្រកាត់ដេរប្រសើរ នៅកម្ពុជា។ គំរោងរោងចក្រកាត់ដេរប្រសើរនៅកម្ពុជា*** ត្រូវបានឧបត្ថម្ភថវិកាដោយ:

អ្នកផ្តល់ជំនួយ

រាជរដ្ឋាភិបាលកម្ពុជា
ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ
សហភាពសហព័ន្ធសហជីពជាតិកម្ពុជា
សហភាពការងារកម្ពុជា
ធនាគារពិភពលោក
ក្រុមនៃអ្នកបញ្ជាទិញអន្តរជាតិ

សំរាប់ពត៌មានបន្ថែមសូមទំនាក់ទំនង:
***រោងចក្រកាត់ដេរប្រសើរនៅកម្ពុជា***
**អង្គការពលកម្មអន្តរជាតិ**
លេខ៩ ផ្លូវលេខ៣២២ បឹងកេងកង១
ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ២៦៤២
ទូរស័ព្ទ : (+៨៥៥) ២៣ ២១២ ៨៤៧
(+៨៥៥) ២៣ ២២០ ៣៦២
ទូរសារ : (+៨៥៥) ២៣ ២១២ ៩០៣
អ៊ីម៉ែល : betterfactories@ilo.org
វិបសាយ: www.betterfactories.org/ilo

# សារសំខាន់ៗដកស្រង់ពីឈុតនេះ

- កុំលួច....
- បើសិនអ្នកលួច អ្នកនឹងត្រូវបណ្តេញចេញពីការងារ
- គ្រប់បុគ្គលិកទាំងអស់ (អ្នកគ្រប់គ្រងសហជីព និងកម្មករ) ត្រូវតែគោរពច្បាប់